នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jul-2011, 10:49
CMS/CFO: Uch Arun

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសមួយផ្សេងទៀត

<u>ដាក់ដោយ៖</u>

ក្រុមមេធាវីការពារក្តី នួន ជា

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រំ ផល្លា

Annebrecht VOSSENBERG

សាស្ត្រាចារ្យ Michael RAMSDEN

<u>ផ្ញើជូន៖</u>

ក្រុមមេធាវីការពារក្តីទាំងអស់

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Andrew CAYLEY

ក្រុមមេធាវីការពារក្តីដើមបណ្តឹងរដ្ឋប្បវេណី

I. សេចក្តីផ្តើម

១. មេធាវីការពារក្តី នួន ជា (ក្រុមមេធាវីការពារក្តី) តទៅនេះសូមដាក់ការកត់សម្គាល់នេះទាក់ទងនឹងការអនុវត្តនៅ អវតក នៃទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ("JCE III") ។

២. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសមួយផ្សេងទៀតដែលអាចអនុវត្តនៅ អវតក ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[1] ។ សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានជាពិសេសដូចខាង ក្រោម: (ក) ថាអាចផ្លាស់ប្តូរការកំណត់បទចោទនៃអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូល JCE III, (ខ)ថា JCE III មានចែងនៅក្នុងច្បាប់បង្កើត អវតក, (គ)ថា JCE III មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង/ឬ ជាគោលការណ៍ទូទៅរបស់ច្បាប់ក្នុងអំឡុងពេលពាក់ព័ន្ធឆ្នាំ ១៩៧៥-១៩៧៩, (ឃ)ថា JCE III មានច្បាប់ចែង និងអាចប្រមើលដឹងទុកជាមុនបានដោយជនជាប់ចោទ, (ង) ថាការអនុវត្ត JCE III សមស្របគ្នាជាមួយកម្មវត្ថុ និងគោលបំណងនៃច្បាប់អន្តរជាតិ ។

៣. ចាប់តាំងពីដើមដំបូងមកមេធាវីការពារក្តីកត់សម្គាល់ថាការអនុវត្តនៅ អវតក នៃ JCE III បានក្លាយជាកម្មវត្ថុនៃការវិវាទយ៉ាងខ្លាំង។ មេធាវីការពារកត់សម្គាល់បន្ថែមទៀតថាការសន្និដ្ឋានដែលធ្វើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងសំណើនេះ ត្រូវបានពិចារណានិងដោះស្រាយរួចមកហើយនៅដំណាក់កាលផ្សេងៗគ្នា ។ ហេតុដូច្នេះ ខណៈដែលរក្សាសិទ្ធិដើម្បីធ្វើការបង្ហាញបន្ថែម និងសម្រាប់គោលបំណងនៃចម្លើយតបនេះ មេធាវីការពារក្តីគាំទ្រជាពិសេសដល់ *(ក)* ការសន្និដ្ឋានដែលធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី[2] និង*(ខ)* ផ្នែកពាក់ព័ន្ធនៃការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះស្តីពី JCE III

---

[1] សូមមើលឯកសារ E100 "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសមួយផ្សេងទៀត, ERN 00708242-00708256 ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១ ("សំណើរបស់ កសព) ។

[2] សូមមើលឯកសារ D97 "ញត្តិប្រឆាំងនឹងការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម ដាក់ដោយមេធាវីការពារក្តី អៀង សារី" ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ERN 00208225-00208240 ។ ឯកសារ D97/7, "ការកត់សម្គាល់បន្ថែមរបស់ អៀង សារី ទាក់ទងនឹងការអនុវត្តនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00244390-00244418 ។ ឯកសារ D97/14/5 "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវ ដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០១០ ERN 00429213-00429253។

នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត" លើសហឧក្រិដ្ឋកម្មរួម ("សេចក្តីសម្រេច JCE")[3] ។

៤. អង្គបុរេជំនុំជម្រះបានយល់ឃើញនៅក្នុងសេចក្តីសម្រេច JCE ថាយុត្តិសាស្ត្រដ៏មានកម្រិតដែលបានលើកមកសំអាងដើម្បីគាំទ្រដល់ JCE III "មិនបានផ្តល់នូវភស្តុតាងគ្រប់គ្រាន់ពីការអនុវត្តស៊ីចង្វាក់គ្នារបស់រដ្ឋ ឬមតិយោបល់របស់ចៅក្រម *opinio juris* នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២ ឡើយ"[4] ។ សេចក្តីសម្រេច JCE ក៏បានយល់ឃើញដែរថាអង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការសម្រេចថា តើប្រព័ន្ធច្បាប់ជាតិមួយចំនួនដែលអាចត្រូវបានចាត់ទុកថាតំណាងឲ្យប្រព័ន្ធច្បាប់សំខាន់ៗរបស់ពិភពលោក ទទួលស្គាល់ JCE III ជាទ្រឹស្តីបង្កើតបានជាគោលការណ៍ទូទៅនៃច្បាប់នោះទេ ដោយសារអង្គបុរេជំនុំជម្រះ "មិនពេញចិត្តឡើយថា ការទទួលស្គាល់បែបនេះអាចព្យាករណ៍បានដោយជនត្រូវចោទក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះ"[5]។ គោលបំណងនៃសេចក្តីសន្និដ្ឋានខាងក្រោមនេះបន្ថែមការគាំទ្រដល់សេចក្តីសម្រេច JCE ទាក់ទងនឹងតម្រូវការផ្នែកច្បាប់ដែលភ្ជាប់មកជាមួយការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវតែស្របជាមួយគោលការណ៍នីត្យានុកូលភាព ។ ផ្អែកលើគោលការណ៍នេះ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូង បដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា ។

II. **សាវតារនីតិវិធី**

៥. កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ មេធាវីការពារក្តី អៀង សារី បានដាក់ញត្តិមួយជំទាស់នឹងការអនុវត្តនៅ អវតក នៃសហឧក្រិដ្ឋកម្មរួម (JCE)[6]។ នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") យល់ឃើញថាទម្រង់ដែលត្រូវបានទទួលស្គាល់ទាំងបីរបស់ JCE

---

[3] សូមមើលឯកសារ D97/16/10 "សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១០ ERN 00486521-00486589 , កថាខណ្ឌ ៤៥, ៧៥-៨៨។

[4] ដូចខាងលើ នៅកថាខណ្ឌទី ៧៧ ។

[5] ដូចខាងលើ នៅកថាខណ្ឌទី ៨៧ ។

[6] សូមមើលអក្សរក្នុងយោងទី ២ ខាងលើ ។

អាចអនុវត្តនៅ អវតក[7] ។ ក្រុមមេធាវីការពារក្តី អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ បានដាក់បណ្តឹងឧទ្ធរណ៍ដោយឡែកពីគ្នាប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត[8]។ នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះយល់ឃើញថា JCE I និង JCE II, មិនមែន JCE III ទេ អនុវត្តនៅ អវតក[9] ។ ក្នុងការមិនទទួលស្គាល់ JCE III ជាទម្រង់មួយនៃការទទួលខុសត្រូវដែលអាចអនុវត្តនៅ អវតក ដីកាដំណោះស្រាយផ្ទុះបញ្ចាំងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[10] ។

III. អំណះអំណាង

៦. សហព្រះរាជអាជ្ញាទទួលស្គាល់ថា អវតក មានកាតព្វកិច្ចផ្នែកច្បាប់ដើម្បីប្រកាន់ភ្ជាប់គោលការណ៍នីត្យានុកូលភាព[11] ។ អនុលោមតាមមាត្រា ៣៣(២)ថ្មី នៃច្បាប់បង្កើត អវតក តុលាការនេះត្រូវតែអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ នឹងដំណើរការសមស្របនៃច្បាប់។ មេធាវីការពារក្តីស្នើសុំឲ្យពិចារណាថាវាជាភារកិច្ចរបស់ អវតក ដើម្បីប្រកាន់ភ្ជាប់បទដ្ឋានអន្តរជាតិនៅពេលសម្រេចបញ្ហាថា តើ JCE III ជាផ្នែកនៃច្បាប់ដែលយកមកអនុវត្តដែរ ឬអត់ ។

ក. យុត្តិសាស្ត្រដែលលើកមកសំអាងដោយសហព្រះរាជអាជ្ញាដើម្បីគាំទ្រ JCE III មិនបំពេញលក្ខខណ្ឌតឹងរឹងនៃសច្ចភាពផ្នែកច្បាប់ឡើយ

---

[7] សូមមើលឯកសារ D97/13 "ដីកាសម្រេចលើការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ERN 00411047-00411056 ។

[8] សូមមើលឯកសារ D97/15/1 "បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាស្តីពីការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩", ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០, ERN 00425765-00425790 ។ ឯកសារ D97/16 "បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាស្តីពីការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០៩, ERN 00416874-00416874 ។ ឯកសារ D97/14/5 "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាស្តីពីការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួល ខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ERN 00429213-00429253។

[9] សេចក្តីសម្រេច JCE ។

[10] ឯកសារ D427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ERN 00604508-00605246 ។

[11] សំណើរបស់ កសព នៅកថាខណ្ឌទី៣២ ។

៧. គោលការណ៍នីត្យានុកូលភាព ដូចដែលបង្ហាញនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងប្រព័ន្ធច្បាប់ជាតិ តម្រូវឲ្យការសម្រេចណាមួយដែលនាំឲ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ គោរពតាមសច្ចភាពផ្នែកច្បាប់[12] ។ ត្រូវតែមានការបញ្ជាក់ច្បាស់លាស់នៅក្នុងការអនុវត្តរបស់រដ្ឋទាក់ទងនឹងនិយមន័យនៃវិធានព្រហ្មទណ្ឌ ដែលមិនត្រូវបានបកស្រាយឲ្យខូចប្រយោជន៍របស់ជនជាប់ចោទឡើយ[13]។ ក្នុងករណីដែលទំហំ និងភាពអាចអនុវត្តបាននៃវិធានព្រហ្មទណ្ឌអន្តរជាតិ បើកឲ្យមានការបកស្រាយច្រើនពេក នោះតុលាការត្រូវយកការបកស្រាយដោយផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ នៅពេលមានវិមតិសង្ស័យ[14]។

---

[12] ការតម្រូវថាការសម្រេចណាមួយត្រូវតែសច្ច មានរឹសគល់នៅក្នុងយុត្តិសាស្ត្រនៃប្រព័ន្ធច្បាប់ជាតិ ។ សូមមើល Kevin Gallant, គោលការណ៍នីត្យានុកូលភាពនៃច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបព្រហ្មទណ្ឌអន្តរជាតិ (*The Principle of Legality in International and Comparative Criminal Law* (Cambridge University Press, 2008), ជំពូកទី ៥។ សូមមើលផងដែរការអត្ថាធិប្បាយរបស់សាស្ត្រាចារ្យ Kai Ambos នៅក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីរបស់គាត់, ឯកសារលេខ D99/3/27, សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីទាក់ទងនឹងសំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/កសចស, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨, ERN 00234912-00234942 នៅទំព័រទី២០ ។

[13] សូមមើលរឿងរដ្ឋអាជ្ញា តទល់ *Vasiljevic*, IT-98-32-T, “សាលក្រមចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ នៅកថាខណ្ឌទី ១៩៨ ។ រឿងរដ្ឋអាជ្ញា តទល់ *Stakić*, IT-97-24-T, “សេចក្តីសម្រេចតាមវិធាន៩៨ស្ទួនលើញត្តិសុំឲ្យមានសេចក្តីសម្រេចឲ្យរួចផុតពីការចោទប្រកាន់” ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០២ នៅកថាខណ្ឌទី១៣១ ។ គោលការណ៍នេះក៏បានត្រូវបានចែងយ៉ាងរឹងមាំនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសិទ្ធិមនុស្ស ។ សូមមើលករណី Kokkinakis តទល់ Greece, បណ្តឹងលេខ 14307/88 និង A260-A, 17 Eur. H.R. Rep. 397 (ser. A) 52, (1993). សូមមើលការអត្ថាធិប្បាយរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិដែលថាតុលាការ ICTY នៅពេលមានវិមតិសង្ស័យ អាចអនុវត្តវិធានទាំងនេះនៃច្បាប់អន្តរជាតិដែលជាផ្នែកនៃច្បាប់អន្តរជាតិតែប៉ុណ្ណោះ UN Doc S/25704, “របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌទី២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣) ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៣ នៅកថាខណ្ឌទី ៣៤ ។

[14] សូមមើល ឧទាហរណ៍ មាត្រា ២២(២) នៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍: “និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែបកស្រាយឲ្យតឹងរឹងបំផុត ហើយមិនត្រូវពន្លាតដោយសទិសភាពឡើយ ។ ក្នុងករណីមានន័យមិនច្បាស់លាស់ និយមន័យត្រូវតែបានបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងតែត្រូវបានស៊ើបអង្កេត ជំនុំជម្រះ ឬ ផ្តន្ទាទោស” សូមមើល A Cassese (Ed), The Oxford Companion to International Criminal Justice (Oxford 2009), នៅទំព័រ 440–441 (*Favor rei* ‘គឺជាគោលការណ៍ […] ដែលតម្រូវឲ្យបកស្រាយក្នុងន័យការពារផលប្រយោជន៍របស់ជនជាប់ចោទក្នុងករណីមានជំនាស់នៃការបកស្រាយ ។ គោលការណ៍នេះក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ ។ សូមមើលមាត្រា ៣៨ (ករណីមានវិមតិសង្ស័យ... […] ត្រូវតែបានដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ”) (បញ្ជាក់បន្ថែម) ។

៨. ផ្អែកលើមូលដ្ឋានសច្ចភាពផ្នែកច្បាប់ ដូច្នេះវាមានន័យយ៉ាងច្បាស់ថា JCE III មិនបង្កើតបានជាផ្នែកនៃច្បាប់ដែលនៅជាធរមានក្នុងអំឡុងដែលពេលពាក់ព័ន្ធនោះទេ ។ ដូចដែលបានកត់សំគាល់នៅក្នុងសេចក្ដីសម្រេច JCE "ចំពោះយុត្តិសាស្ត្រអន្តរជាតិដែលរឿងក្ដី Tadic បានផ្អែកនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថាអង្គហេតុនៃរឿងក្ដី *Borkum Island* និង *Essen Lynching* ពិតណាស់អាចពាក់ព័ន្ធដោយផ្ទាល់ទៅនឹង JCE III ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមិនមានសាលក្រមសំអាងហេតុនៅក្នុងរឿងក្ដីគេមិនអាចដឹងប្រាកដអំពីមូលដ្ឋាននៃការទទួលខុសត្រូវ ដែលសម្រេចដោយតុលាការយោធាឡើយ"[15]។ អ្នកធ្វើអត្ថាធិប្បាយក៏មានមន្ទិលសង្ស័យយ៉ាងខ្លាំងទាក់ទងនឹងភាពអាចជឿទុកចិត្តបាននៃយុត្តិសាស្ត្រដែលត្រូវបានលើកមកសំអាងដើម្បីគាំទ្រ JCE III នោះ ដែលត្រូវបានប្រើប្រាស់ក្នុងន័យប្រឌិតដើម្បីធ្វើសនិទានភាព ជាការគាំទ្រដល់ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយបែបទៀត[16] ។ ដោយមើលឃើញពីភាពកម្រនៃយុត្តិសាស្ត្រអន្តរជាតិទាក់ទងនឹង JCE III ក្នុងអំឡុងពេលដែលពាក់ព័ន្ធ ដូច្នេះវាគ្មានអ្វីភ្ញាក់ផ្អើលទេ កាលដែលសហព្រះរាជអាជ្ញាផ្អែកជាថ្មីម្ដងទៀតលើករណីដូចគ្នាដែលៗនៅក្នុងសំណើរបស់ពួកគេទៅកាន់អង្គជំនុំជម្រះសាលាដំបូង ជាសំណើដូចគ្នាដែលត្រូវបានបដិសេធចោលដោយអង្គបុរេជំនុំជម្រះ ថាគ្មានមូលដ្ឋាននៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ដែលជាដំណោះស្រាយតែមួយគត់ដែលស៊ីចង្វាក់ជាមួយគោលការណ៍នីត្យានុកូលភាពនោះ ។

ខ. JCE III មិនអាចប្រមើលដឹងទុកជាមុន និងមិនអាចដឹងថាមានចែងក្នុងច្បាប់ដោយជនជាប់ចោទក្នុងអំឡុងពេលដែលពាក់ព័ន្ធបានទេ

[15] សេចក្ដីសម្រេច JCE នៅកថាខណ្ឌទី៧៩ (បញ្ជាក់បន្ថែម) ។

[16] Elies van Sliedregt "ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ (*The Criminal Responsibility of Individuals for Violations of International Humanitarian Law* (Asser Press, The Hague, 2003) នៅទំព័រទី 27, 31 ។ Stephen Powles, "សហឧក្រិដ្ឋកម្មរួម: ការទទួលខុសត្រូវព្រហ្មទណ្ឌដោយភាពប៉ិនប្រសប់របស់រដ្ឋអាជ្ញា និងភាពច្នៃប្រឌិតរបស់ចៅក្រម" 'Joint Criminal Enterprise: Criminal Liability by Prosecutorial Ingenuity and Judicial Creativity', (2004) 2 (ទិន្នានុប្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌ) *Journal of International Criminal Justice*, នៅទំព័រ. 606-619 ។ Luke Marsh & Michael Ramsden, "សហឧក្រិដ្ឋកម្មរួម: ការឆ្លើយតបរបស់កម្ពុជាទៅនឹងរឿងក្ដី Tadic, ១១ (២០១១) *International Criminal Law Review*, 137-154, នៅទំព័រ 149-150 ។

៩. ជាមួយសញ្ញាណនៃយុត្តិធម៌ជាមូលដ្ឋាន វាត្រូវបានសន្មតថាជនត្រូវចោទត្រូវតែបានដឹងថាអំពើជាក់លាក់ នឹងនាំឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ វាចាំបាច់រកឲ្យឃើញថាបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវនេះ អាចប្រមើលដឹងទុកជាមុន និងដឹងថាមានច្បាប់ចែង ។ ការប្រមើលដឹងទុកជាមុន អាចវាយតម្លៃបានពីទិដ្ឋភាពរបស់ជនជាប់ចោទ ដែលតម្រូវឲ្យពិចារណាថាតើអំពើនោះត្រូវបានហាមឃាត់ដោយច្បាប់ជាតិនៃប្រទេសរបស់ជនជាប់ចោទនៅពេលវេលាពាក់ព័ន្ធដែរ ឬអត់[17] ។

១០. សហព្រះរាជអាជ្ញាបានលើកឡើងថាអង្គបុរេជំនុំជម្រះភ័ន្តច្រឡំក្នុងការពិនិត្យមើលច្បាប់កម្ពុជានៅពេលវាយតម្លៃថាតើ JCE III អាចប្រមើលដឹងជាមុនដោយជនជាប់ចោទដែរឬអត់[18]។ ជាពិសេសសហព្រះរាជអាជ្ញាបានលើកឡើងថាចរិតធម្មជាតិនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ណែនាំពីចំណុចចាប់ផ្ដើមក្នុងកម្រិតទាបនៃការប្រមើលដឹងជាមុននេះ[19]។ ប៉ុន្តែតាមការជាក់ស្ដែង កម្រិតចាំបាច់ដើម្បីកំណត់ថា

---

[17] សូមមើលរឿងក្ដីរដ្ឋអាជ្ញា តទល់ *Milutionvic, Sainovic និង Ojdanic*, IT-99-37-AR72, "សេចក្ដីសម្រេចលើសំណើរបស់ Dragolijub Ojdanic ជំទាស់នឹងយុត្តាធិការលើសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ នៅកថាខណ្ឌទី៤០ ("សេចក្ដីសម្រេច *Ojdanic*") ។ រឿងក្ដីរដ្ឋអាជ្ញា តទល់ *Vasiljevic*, IT-98-32-T, "សាលក្រមរបស់សាលាដំបូង" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ នៅកថាខណ្ឌទី១៩៩ ។

[18] សំណើរបស់ កសព នៅកថាខណ្ឌទី ៣៥ ។

[19] ដូចខាងលើ ជាពិសេសសហព្រះរាជអាជ្ញាទាញសេចក្ដីសន្និដ្ឋានពីយុត្តិសាស្ត្រដ៏មានកម្រិតរបស់ ICTY ដើម្បីបញ្ជាក់ថាភាពអាចព្យាករណ៍ជាមុនបាន និងថាអាចដឹងថាមានច្បាប់ចែង កាត់ដាច់ចេញពីគ្នានៃការវាយតម្លៃផ្នែកច្បាប់ ដែលត្រូវបានសន្មត់ថាអំពើនោះជាផ្នែកច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ ទោះជាយ៉ាងនេះក្ដី អវតក ត្រូវតែប្រុងប្រយ័ត្នក្នុងការអនុវត្តតាមយុត្តិសាស្ត្ររបស់ ICTY ដែលយុត្តិសាស្ត្រទាំងនេះ គឺមានបរិបទខាងច្បាប់ និងប្រវត្តិសាស្ត្រខុសគ្នា។ ជាបឋម លក្ខន្តិកៈរបស់ ICTY មិនមានចែងច្បាស់លាស់បីគោលការណ៍នីត្យានុកូលភាពទេ ។ ផ្ទុយទៅវិញ អវតក គឺជាតុលាការកម្ពុជា ហើយត្រូវតែគោរពតាមគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា(មាត្រា ៣១, ៣៨) , ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៥៦ (មាត្រា ៦) និងច្បាប់ អវតក (មាត្រា ៣៣(២) ថ្មី ។ ទីពីរ កម្រិតនៃភាពអាចព្យាករណ៍ជាមុនបាន និងកាដឹងថាមានចែងនៅក្នុងច្បាប់ដែលត្រូវបានសន្មតនៅ ICTY ត្រូវយកមកពិចារណាការវិវឌ្ឍន៍របស់ច្បាប់ព្រហ្ម ទណ្ឌអន្តរជាតិ (រួមទាំងការរីកដុះដាលនៃការបោះពុម្ពផ្សាយដោយចៅក្រម) ជាងកន្លះសហវត្សមកនេះ ។ យុត្តិសាស្ត្ររបស់ ICTY គឺកំពុងតែត្រូវបានអភិវឌ្ឍ ដូចជាការអភិវឌ្ឍនានាដែលពាក់ព័ន្ធនៅក្នុងច្បាប់ដ៏ទៃទៀត ។ ផ្ទុយទៅវិញ យុត្តាធិការពេលវេលារបស់ អវតក ត្រូវបានដាក់កម្រិតយ៉ាងតឹងរឹងចំពោះការអនុវត្តច្បាប់ ដោយសារវាកើតឡើងនៅមុនការអភិវឌ្ឍនៃច្បាប់សហកាលព្រហ្មទណ្ឌ អន្តរជាតិ ។ សូមមើល Beth Van Schaack, 'Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals', *The Georgetown Law Journal,* Vol. 97:119(២០០៨), នៅទំព័រ 182. ។

តើអ្វីខ្លះដែលជនជាប់ចោទអាចប្រមើលដឹងទុកមុនបាន ដោយផ្អែកលើច្បាប់ជាតិនៃប្រទេសរបស់ខ្លួន គឺអាស្រ័យលើកម្រិតប្រភពច្បាប់អន្តរជាតិដែលអាចកំណត់អំពើរបស់ជនជាប់ចោទ[20]។ ផ្ទុយមកវិញ ប្រសិនបើគ្មានការសម្រេចរបស់តុលាការ និងលិខិតុបករណ៍អន្តរជាតិណាមួយទេ នោះវាជាការសំខាន់ដើម្បីពិនិត្យមើលច្បាប់ជាតិរបស់ជនជាប់ចោទដើម្បីវាយតម្លៃថា តើជនជាប់ចោទបានដឹងដោយសមហេតុផលថាការប្រព្រឹត្តណាមួយ អាចធ្វើឱ្យខ្លួនជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមច្បាប់អន្តរជាតិដែរ ឬអត់ ។ សម្រាប់មូលហេតុដែលបានលើកឡើងក្នុងចំណុច (ក) ខាងលើ ភាពមិនច្បាស់លាស់ច្បាស់ក្រឡែតទាក់ទងនឹង JCE III ដោយផ្អែកតែលើយុត្តិសាស្ត្រតិចតួច តម្រូវឱ្យ អវតក ពិចារណាយ៉ាងដិតដល់អំពីភាពអាចប្រមើលទុកជាមុនបានពីទិដ្ឋភាពរបស់ជនជាប់ចោទដោយផ្អែកតាមច្បាប់កម្ពុជា ។

១១. មេធាវីការពារក្តីយល់ឃើញថាវិធីសាស្ត្រដូចគ្នានេះ បើពិចារណាពីភាពអាចប្រមើលដឹងទុកជាមុនពីទិដ្ឋភាពរបស់ជនជាប់ចោទដោយផ្អែកលើច្បាប់កម្ពុជា ក៏អាចជួយបានដែរនៅពេលធ្វើការបញ្ជាក់ថាតើ JCE III បានកើតឡើងជាគោលការណ៍ច្បាប់ទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ឬអត់[21]។ វានឹង

---

[20] សេចក្តីសម្រេច *Ojdanic* នៅកថាខណ្ឌទី ៤០-៤០ ត្រូវបានកត់សំគាល់នៅក្នុងរឿងក្តី *Ojdanic* ថាមាន "ការស៊ីចង្វាក់គ្នានៃការសេចក្តីសម្រេចរបស់តុលាការ, លិខិតុបករណ៍អន្តរជាតិ និងច្បាប់ជាតិ ដែលនឹងអនុញ្ញាតឱ្យបុគ្គលណាមួយគ្រប់គ្រងទង្វើរបស់ខ្លួនស្របតាមបទបញ្ញត្តិទាំងនេះ (កថាខណ្ឌទី៤១)។ (បញ្ជាក់បន្ថែម) ។

[21] សូមមើលសេចក្តីសម្រេច JCE ក្នុងករណីដែល អបជ អនុវត្តលក្ខណ្ឌនៃភាពអាចប្រមើលទុកជាមុនបាន ដើម្បីកំណត់ ថាតើគោលការណ៍ច្បាប់ទូទៅដែលបានអះអាងនឹងបំពេញគោលការណ៍នីត្យានុកូលភាពដែរ ឬអត់, ត្រង់កថាខណ្ឌទី៨៧។ សូមមើលបន្ថែមទៀត មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ដែលចែងថា ច្បាប់ព្រហ្មទណ្ឌមិនបានឥទ្ធិពលប្រតិសកម្មឡើយ ។ គ្មានបទឧក្រិដ្ឋណាមួយអាចត្រូវបានដាក់ទោសបានទេ តាមទោសរបស់ច្បាស់ដែលនឹងបញ្ញត្តិថ្មីបានទេ ។ មាត្រា ៦ បានប្រើប្រាសពាក្យដាច់ខាត ហើយមិនមានការលើកលែងឡើយ ។ ICCPR ដែលអាចអនុវត្តចំពោះនីតិវិធីទាំងនេះដោយអំណាចមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា "រក្សាសន្តភាពនៃច្បាប់ណាមួយដែលផ្តល់ការការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងកម្រិតខ្ពស់ជាង ICCPR ។ (សូមមើលឯកសារ D427/1/6 "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ 00617486–00617631, នៅក្នុងអក្សរក្នុងលេខយោងលេខ ២១០ (នលើកមកសំអាង Manfred Nowak, UN Covenant on Civil and Political Rights: ICCPR Commentary 118 (NP Engel 2005)); ICCPR, នៅមាត្រា ៥(២) ។ ហេតុដូច្នេះ អវតក ជាតុលាការកម្ពុជា មានករណីយកិច្ចគោរពគោលការណ៍នីត្យានុកូលភាពដែលតម្រូវដោយច្បាប់កម្ពុជា និងត្រូវតែយកមកពិចារណាភាពលើទិដ្ឋ

មិនសមហេតុផលឡើយក្នុងការលើកឡើងថាជនជាប់ចោទបានដឹងថា JCE III គឺជាគោលការណ៍ច្បាប់ទូទៅ ជាពិសេសបើពិនិត្យលើករណីដែលថា ទម្រង់នៃការទទួលខុសត្រូវបែបនេះ គ្មានចែងនៅក្នុងប្រព័ន្ធច្បាប់ជាតិសំខាន់ជាច្រើននោះទេ[22] ។ សហព្រះរាជអាជ្ញាបានព្យាយាមដាក់បញ្ចូលវិធីសាស្ត្រទាំងស្រុងក្នុងរឿងក្ដី Tadic ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ទៅក្នុង អវតក លើកលែងតែនៅពេលដែលការសំអាងហេតុបែបនេះមិនបានផ្ដល់លទ្ធផលដែលខ្លួនចង់បាន ។ ក្នុងរឿងក្ដី *Tadic* តុលាការកំពូលរបស់ ICTY បានកត់សម្គាល់ថា "វាជាការចាំបាច់ដែលត្រូវបង្ហាញថាប្រទេសភាគច្រើន បើសិនមិនទាំងអស់ទេនោះ ត្រូវតែទទួលយកគោលគំនិតដូចគ្នានៃគោលបំណងរួម ។ ច្បាស់ជាងនេះទៅទៀតក្នុងករណីណាក៏ដោយ គេចាំបាច់ត្រូវបង្ហាញថាប្រព័ន្ធច្បាប់សំខាន់របស់ពិភពលោកប្រកាន់យកវិធីសាស្ត្រដូចគ្នាចំពោះគោលគំនិតនេះ[23]។ បន្ទាប់ពីមានការស្ទង់មតិមួយ តុលាការកំពូលរបស់ ICTY បានសន្និដ្ឋានថា JCE III មិនអាចត្រូវបានធ្វើឱ្យទៅជាគោលការណ៍ច្បាប់ទូទៅបានទេ បើពិនិត្យមើលភាពខុសគ្នាក្នុងវិធីសាស្ត្រចំពោះការទទួលខុសត្រូវលើផែនការរួម[24]។ ក្នុងន័យនេះសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាអញ្ជើញឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដីលើបញ្ហានេះ បញ្ជាក់ឡើងវិញពីវិសមតិភាព JCE III ជាគោលការណ៍ច្បាប់ទូទៅជាមួយគោលការណ៍នីត្យានុកូលភាព៖ ប្រសិនបើការសិក្សាដ៏ស៊ីជម្រៅមួយអំពីយុត្តាធិការក្នុងអំឡុង

ភាពរបស់ជនជាប់ចោទពីភាពអាចប្រមើលមើលទុកជាមុននៃច្បាប់អន្តរជាតិ ទាក់ទងនឹងច្បាប់កម្ពុជាក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

[22] សូមមើលរឿងក្ដីរវាងរដ្ឋអាជ្ញា តទល់ *Tadic*, IT-94-1-A, "សាលក្រម *Tadic* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ នៅកថាខណ្ឌទី ២២៤ ។ សូមកត់សំគាល់ដែរថាមានវិនិតិសង្ស័យយ៉ាងខ្លាំងអំពីថាតើគោលការណ៍ទូទៅ ជាប្រភពនៃច្បាប់អាចបំពេញបានគោលការណ៍ នីត្យានុកូលភាពតឹងរឹង ដោយថាគោលការណ៍ទូទៅជាអរូបីយ ហើយដូច្នេះវាជាគោលការណ៍ប្រចក្សុះ សូមមើល Machteld Boot, 'Genocide, Crimes Against Humanity, War Crimes: *Nullum Crimen Sine Lege* and the Subject Matter Jurisdiction of the International Criminal Court' (Intersentia Uitgevers N V, 2002), p 300; Fabián O Raimondo, 'General principles of law in the decisions of international criminal courts and tribunals' (Martinus Nijhoff, 2008), នៅទំព័រទី២ ។

[23] សាលក្រម *Tadic* នៅកថាខណ្ឌទី២២៥ ។

[24] ដូចខាងលើ ។ ម្យ៉ាងទៀតដូចដែលអង្គបុរេជំនុំជម្រះបានកត់សំគាល់នៅក្នុងកថាខណ្ឌទី៨៤ នៃសាលដីកា JCE "ប្រព័ន្ធច្បាប់ខុសៗគ្នាមានលក្ខណៈខុសទាក់ទងនឹងបំណងឧក្រិដ្ឋដែលតម្រូវ ដើម្បីដាក់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះជនជាប់ចោទសម្រាប់បទល្មើសដែលប្រព្រឹត្តឡើងដោយបុគ្គលដទៃដែលប្រព្រឹត្តលើសពីអ្វីដែលជនជាប់ចោទមានបំណង ។ ចំណុចនេះអាចពន្យល់ថាហេតុអ្វីបានជាសាលក្រម *Tadic*, បានប្រើពាក្យខុសៗគ្នាដើម្បីបញ្ជាក់ពីន័យនានាដែលកំណត់ធាតុផ្សំនៃចេតនាចំពោះ JCE III ។

កម្ពុជាប្រជាធិបតេយ្យដោយបញ្ញាជន មានសារៈសំខាន់ក្នុងការដោះស្រាយមន្ទិលសង្ស័យរបស់សហព្រះរាជអាជ្ញាលើការយល់ឃើញក្នុងសំណុំរឿង *Tadic* លើចំណុចនេះ នោះគេមិនអាចនិយាយបានថា JCE III ជាគោលការណ៍ច្បាប់ទូទៅដែលជនជាប់ចោទអាចប្រមើលទុកជាមុនបានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

១២. សេចក្តីសម្រេច JCE បានទទួលស្គាល់ថាមិនមានបទបញ្ញត្តិក្នុងច្បាប់កម្ពុជាដែលនៅជាធរមានក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលអាចឱ្យជនជាប់ចោទដឹងថាទម្រង់នៃការទទួលខុសត្រូវមាននៅក្នុង JCE III អាចផ្តន្ទាទោសបាននោះទេ[25] ។ គេក៏ត្រូវពិចារណាផងដែរគំនិតរបស់លោក Kai Ambos ក្នុងសារណារបស់អ្នកដែលមិនមែនភាគីក្នុងរឿងក្តីរបស់គាត់ដែលថា JCE III ពិតជាមិនបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឡើយ[26]។ មេធាវីការពារក្តីយល់ឃើញថាការកត់សម្គាល់ទាំងនេះបានបង្ហាញពីការសន្និដ្ឋានដែលមិនអាចផ្លាស់ប្តូរបានដែលថា ការពន្លាតសញ្ញាណ JCE គឺផ្ទុយទាំងស្រុងទៅនឹងច្បាប់កម្ពុជាក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះហើយជនជាប់ចោទមិនអាចប្រមើលដឹងទុកជាមុនបានឡើយ។

១៣. នៅទីបញ្ចប់ សហព្រះរាជអាជ្ញាបានអះអាងថា JCE III អាចប្រមើលទុកជាមុនបានបើពិនិត្យមើលលើលក្ខណៈធម្មជាតិរបស់បទល្មើសដែលបានប្រព្រឹត្ត[27] ។ ផ្ទុយទៅវិញ ក្នុងករណីដែលបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដោយផ្ទាល់ បុគ្គលនោះគួរតែដឹងថាការប្រព្រឹត្តរបស់ខ្លួនសមតែទទួលទោសព្រហ្មទណ្ឌ ប៉ុន្តែវាជាការមិនត្រឹមត្រូវឡើយដែលអះអាងថាអ្នកដែលចូលរួមក្នុងផែនការរួម នឹងអាចប្រមើលទុកជាមុនបានអំពីការទទួលខុសត្រូវចំពោះទង្វើដែលបានប្រព្រឹត្តដោយអ្នកដទៃ ដែលស្ថិតនៅក្រៅពីវិសាលភាពនៃផែនការដើម ។ ជាពិសេសយុត្តិសាស្ត្រអន្តរជាតិលើកឡើងថាគោលបំណងរួមនៃ JCE មិនចាំបាច់ទាល់តែខុសច្បាប់ឡើយ[28]។ ក្នុងករណីបែបនេះ ជនជាប់ចោទមិនអាចប្រមើលដឹងជា

[25] សេចក្តីសម្រេច JCE នៅកថាខណ្ឌទី៨៧ ។

[26] សូមមើលអក្សរក្នុងលេខយោងលេខ ១២ ខាងលើ ទំព័រទី៣០។

[27] សេចក្តីសន្និដ្ឋានរបស់ កសព នៅកថាខណ្ឌទី៣៦ ។

[28] សូមមើលឧទាហរណ៍រឿងក្តីរដ្ឋអាជ្ញាតទល់ *Alex Tamba Brima, Brima Bazzy Kamara, Santigie Borbor Kanu*, SCSL-2004-16-A, ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៅកថាខណ្ឌទី៧៦, ៨៤ (សំអាងនៅក្នុងឯកសារD97/14/5.2 (សារណា JCE ដោយមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ERN 00440434–00440481)។

មុនឲ្យបានគ្រប់គ្រាន់ដែលថាទង្វើស្របច្បាប់របស់ពួកគេអាចប្រឈមនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ[29] ។

IV. សេចក្តីសន្និដ្ឋាន

១៤. អាស្រ័យដូចមានមូលហេតុដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញាសុំការអនុវត្ត JCE III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសមួយផ្សេងទៀត ។ ដូចដែលបានគូសបញ្ជាក់ពីខាងលើ[30] មេធាវីការពារក្តីសូមរក្សាសិទ្ធិធ្វើសេចក្តីសន្និដ្ឋាន និងដាក់សារណាជាលាយលក្ខអក្សរបន្ថែមទៀតដើម្បីជាប្រយោជន៍យុត្តិធម៌ ។

សហមេធាវីការពារក្តីលោក នួន ជា

សុន អរុណ Michel PESTMAN & Victor KOPPE

[29] ប្រសិនបើ អវតក មានបំណងពិចារណាវិធីសាស្ត្ររបស់ កសព ដោយប្រើប្រាស់អំណះអំណាងមិនរីកចំរើនដើម្បីធ្វើយុត្តិកម្មដាក់ទម្រង់នៃការទទួលខុសត្រូវឈានទៅរកការផ្តន្ទាទោស នោះ អវតក ត្រូវពិចារណាពីការថ្កោលទោសទៅលើ JCE III ដោយសហគមន៍អន្តរជាតិ ។ ជាពិសេស មានការកត់សំគាល់ថា JCE III "បន្ថយការគោរពយុត្តិធម៌អន្តរជាតិធ្វើឲ្យចុះខ្សោយការកេរ្តិ៍ឈ្មោះពិរុទ្ធភាពរបស់តុលាការមួយ និងធ្វើឲ្យអន្តរវាយកេរ្តិ៍ដំណែលជាប្រវត្តិសាស្ត្ររបស់តុលាការ" ។ សូមមើល William A. Schabas, 'Mens Rea and the International Criminal Tribunal for the Former Yugoslavia', 37 (2002–2003), *New England Law Review*, pp 1033–34; Luke Marsh & Michael Ramsden, n, *supra*, pp 153–154;. Jens David Ohlin, 'Three Conceptual Problems with the Doctrine of Joint Criminal Enterprise', 5 (2007), *Journal of International Criminal Justice*, 69–90 ។ បើសិនភាពធ្ងន់ធ្ងរខាងសីលធម៌របស់បទល្មើសដែលត្រូវចោទប្រកាន់នៅក្នុងដីកា ដំណោះស្រាយធ្វើយុត្តិកម្មចំពោះ ការងាកចេញពីគោលការណ៍នីត្យានុកូលភាព ។ តែ "វាប្រាកដណាស់ ថានៅពេលដែលអំពើដែលស្អប់ខ្ពើម និងដែលរន្ធត់ ដែលនោះគោលការណ៍នីត្យានុកូលភាពត្រូវតែបានអនុវត្តឲ្យបានតឹងរឹងបំផុត ដើម្បីធានាថាជនជាប់ចោទ មិនត្រូវបានផ្តន្ទាទោសដោយការស្អប់ខ្ពើម តែដោយភស្តុតាង" ។ សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់ *Hinga Norman*, SCSL-2004-14-AR72(E), មតិខ្វែងរបស់ចៅក្រម Robertson សេចក្តីសម្រេចលើញត្តិបឋមស្តីពីការគ្មានយុត្តាធិការ (ការជ្រើសរើសទាហានកុមារ) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ នៅកថាខណ្ឌទី ១២ ។

[30] សូមមើលកថាខណ្ឌទី៣ ខាងលើ ។